**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៣-០១២ ប្រ.ក

# ប្រកាស

## ស្តីពី

## ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមប្រកាសលេខ ធ៨-៩៩-១៤៧ ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន
- យោងតាមការសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៣

## សំរេច

**ប្រការ ១.-**

កំណត់នីតិវិធីសំរាប់ការអនុវត្តន៍ប្រព័ន្ធរបាយការណ៍ពីប្រតិបត្តិការអន្តរជាតិសំរាប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រតិស្រុតិដែលតទៅនេះហៅកាត់ថា "គ្រឹះស្ថានហិរញ្ញវត្ថុ" ។

នីតិវិធីនិងបែបបទបំពេញរបាយការណ៍មានរៀបរាប់ក្នុងឯកសារ (International Transactions Reporting System: Classification & Procedures Manual, December 2002) ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ។

**ប្រការ ២.-**

គោលបំណងនៃការអនុវត្តន៍ប្រព័ន្ធរបាយការណ៍ពីប្រតិបត្តិការអន្តរជាតិ គឺដើម្បីប្រមូលទិន្នន័យស្តីពីប្រតិបត្តិការអន្តរជាតិដែលធ្វើឡើងតាមរយៈគណនីរបស់អតិថិជននៅធនាគារជាតិនៃកម្ពុជានិងគ្រឹះស្ថានហិរញ្ញវត្ថុ សំរាប់តម្លើងស្ថិតិជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា ។

**ប្រការ ៣.-**

នាយកដ្ឋានពាក់ព័ន្ធនិងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវផ្តល់ពតិមានរៀងរាល់ខែអោយបានត្រឹមត្រូវ និងទាន់ពេលវេលាមកនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចមិនអោយលើសពី១០ថ្ងៃធ្វើការ ក្រោយខែនិមួយៗ ។ ក្នុងករណីពុំទាន់មានពតិមានគ្រប់គ្រាន់ និងត្រឹមត្រូវ នាយកដ្ឋានពាក់ព័ន្ធនិងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវផ្តល់ពតិមានប៉ាន់ស្មានមកនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចក្នុងរយៈពេលធ្វើរបាយការណ៍ដែលបានតម្រូវ ហើយនឹងត្រូវផ្តល់ពតិមានជាក់ស្តែងនៅពេលរៀបចំរួច ។

**ប្រការ ៤.-**

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចត្រូវធានារក្សាការសម្ងាត់ចំពោះពតិមានដែលទទួលបានពីនាយកដ្ឋានពាក់ព័ន្ធនិងគ្រឹះស្ថានហិរញ្ញវត្ថុ ។ ពតិមាននេះនឹងត្រូវបានប្រើប្រាស់សំរាប់តែការតម្លើងស្ថិតិ និងចេញផ្សាយក្នុងរូបភាពជារបាយការណ៍ និងស្ថិតិសរុបរួមប៉ុណ្ណោះ ។

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចត្រូវពិនិត្យ និងបូកសរុបរបាយការណ៍ដែលនាយកដ្ឋានពាក់ព័ន្ធនិងគ្រឹះស្ថានហិរញ្ញវត្ថុបានផ្ញើមក ហើយត្រូវបញ្ចូលក្នុងស្ថិតិជញ្ជីងទូទាត់ប្រចាំគ្រារបស់ប្រទេសកម្ពុជា ។

**ប្រការ ៥.-**

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចអាចនឹងពិនិត្យមើលឡើងវិញនូវប្រព័ន្ធរបាយការណ៍ពីប្រតិបត្តិការអន្តរជាតិ សំដៅកែលំអ និងសំរាលបន្ទុកចំណាយក្នុងការធ្វើរបាយការណ៍ ។

**ប្រការ ៦.-**

ឯកសារដែលមានភ្ជាប់ជាឧបសម្ព័ន្ធ (ITRS Classification & Procedures Manual, December 2002) និងឯកសារទាំងអស់ដែលបានទទួល ឬរៀបចំដោយធនាគារជាតិនៃកម្ពុជា គឺសំរាប់ប្រើប្រាស់តែក្នុងការតម្លើងស្ថិតិជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាប៉ុណ្ណោះ ហើយគឺជាកម្មសិទ្ធិផ្តាច់មុខរបស់ធនាគារជាតិនៃកម្ពុជាដែលមិនអាចត្រូវថតចម្លង ឬបញ្ជូនដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីធនាគារជាតិនៃកម្ពុជាឡើយ ។

**ប្រការ ៧.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឹងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៣

ទេសាភិបាល

ជា ចាន់តូ

__**កន្លែងទទួល**__ :

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

__**ចម្លងជូន**__ :

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"